ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ : ០១៩/១៧ គ.ជ.ប.ជ

# កំណត់ហេតុ
## សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការពង្រឹងការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែធ្នូ ថ្ងៃទីម្ភៃមួយ វេលាម៉ោងប្រាំបីព្រឹក នៅសណ្ឋាគារអាំងទែកុងទីណង់តាល់ មានបើកសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការពង្រឹងការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី និងជាប្រធាន គ.ជ.ប.ជ** ។ សមាសភាពចូលរួមអង្គសិក្ខាសាលាសរុបចំនួន ១៥៩នាក់ (ស្រី ៤៧នាក់) ។

ជាបឋម **លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានឡើងមានមតិស្វាគមន៍ និងថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងនគរបាលជាតិ និងអង្គការដៃគូពាក់ព័ន្ធទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសិក្ខាសាលា ។ ជាបន្ត លោកជំទាវបានមានប្រសាសន៍អំពីគោលបំណងដែលអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ បានផ្តួចផ្តើមរៀបចំសិក្ខាសាលាថ្នាក់ជាតិនេះឡើង គឺដើម្បីពិនិត្យឡើងវិញនូវភាពខ្វះចន្លោះនៃបទដ្ឋានច្បាប់ នីតិវិធី និងរបៀបរបបអនុវត្តឲ្យរឹតតែប្រសើរឡើង ដោយហេតុថាកន្លងមកសង្កេតឃើញថា ទោះបីជាមានច្បាប់ច្រើនហើយក្តីក៏ការអនុវត្តនៅតែមិនទាន់អាចធ្វើឲ្យបទល្មើសថមថយ ហើយនៅតែកើតមានដដែលៗទៅលើជនរងគ្រោះកាន់តែច្រើន ដែលក្នុងនោះជនរងគ្រោះទាំងឡាយជាពិសេសជនរងគ្រោះដោយអំពើជួញដូរមនុស្សកម្របានទទួលនូវសំណងបដិទានសមស្របសម្រាប់ប៉ះប៉ូវការខូចខាតណាស់ ហេតុនេះហើយបញ្ហានេះបានបង្កនូវអវិភាពដល់ប្រជាពលរដ្ឋ កាន់តែភ័យខ្លាច ឬកាន់តែព្រងើយកន្តើយចំពោះការអនុវត្តច្បាប់ និងនៅតែប្រថុយប្រថាននឹងគ្រោះថ្នាក់។ លោកជំទាវបានសង្ឃឹម និងមានជំនឿថា សិក្ខាសាលាថ្នាក់ជាតិនេះនឹងទទួលបានផ្លែផ្កាយ៉ាងជាក់លាក់ និងល្អប្រសើរតាមការគ្រោងទុកសំដៅដោះស្រាយបញ្ហាកង្វល់ទាំងនេះបាន។

ជាបន្ត តំណាងក្រសួងពាក់ព័ន្ធបានឡើងធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលការងារពាក់ព័ន្ធដែលក្រសួងសាមីសម្រេចបាន ៖

**លោកជំទាវ ខៀវ សុផានី អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌** បានមានប្រសាសន៍អំពីចំណុចសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធនឹងការងាររបស់ក្រសួងយុត្តិធម៌ មានដូចខាងក្រោម ៖

- **យន្តការទទួលបណ្តឹង និងតាមដាន ៖** ដំណើរនីតិវិធីក្នុងការដោះស្រាយសំណុំរឿងពាក់ព័ន្ធនឹងការជួញដូរមនុស្ស គឺមានរយៈពេលជាមធ្យមលើសពីមួយឆ្នាំនៅសាលាដំបូងរាជធានី-ខេត្ត ឬអាចលើពីនេះក្នុងករណីមានបញ្ហាស្មុគស្មាញ ហើយក្នុងករណីការដោះស្រាយអូសបន្លាយរយៈពេលយូរ ក្រសួងយុត្តិធម៌មានយន្តការទទួលបណ្តឹង និងតាមដាន ដែលភាគីអាចដាក់បណ្តឹងមកក្រសួង ដើម្បីស្នើសុំឲ្យមានការជួយជំរុញដំណើរការនីតិវិធីតុលាការ និងការផ្តន្ទាទោស តែកន្លងមកទាក់ទងនឹងសំណុំរឿងក្តីជួញដូរគឺមិនទាន់មានប្រើប្រាស់យន្តការនេះឲ្យបានទូលំទូលាយនៅឡើយ ។

- **គម្រោងសម្របសម្រួលសាក្សីជនរងគ្រោះ** ៖ ក្នុងការទទួលខុសត្រូវការពារជនរងគ្រោះ ក្រសួងយុត្តិធម៌ទទួលស្គាល់ថា មានឧបសគ្គជាច្រើនក្នុងការជំរុញឲ្យជនរងគ្រោះចូលរួមក្នុងនីតិវិធីនៃដំណើរការរឿងក្តីជួញដូរ ហើយដើម្បីកែលម្អសមត្ថភាពរបស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ចបានចុះអនុស្សរណៈជាមួយអង្គការ AAPTIP ស្តីពីគម្រោងសម្របសម្រួលសាក្សីជនរងគ្រោះ នៅក្នុងឆ្នាំ២០១៥ ដែលជាលទ្ធផល ជួយសម្រួលបាន ៨សំណុំរឿង ដោយបានសម្រួលជាមួយព្រះរាជអាជ្ញាជាប្រចាំ គឺជួយជនរងគ្រោះតាំងពីពេលចាប់ផ្តើមរហូតចប់រឿងក្តី ។ លោកជំទាវបានសំណូមពរឲ្យចៅក្រម-ព្រះរាជអាជ្ញាជួយឲ្យមានអ្នកសម្របសម្រួលកាន់តែច្រើន ។
- **សំណងរដ្ឋប្បវេណីនៅក្នុងរឿងក្តីពាក់ព័ន្ធនឹងការជួញដូរមនុស្ស** ៖ ការទទួលបានសំណងរបស់ជនរងគ្រោះគឺជាបណ្តឹងរដ្ឋប្បវេណីដែលជាប់ជាមួយបណ្តឹងព្រហ្មទណ្ឌ ដូចនេះដើម្បីអាចឲ្យតុលាការសម្រេចលើសំណងរដ្ឋប្បវេណី សេចក្តីសម្រេចផ្តន្ទាទោសទៅលើពិរុទ្ធជនត្រូវតែចូលជាស្ថាពរ ហើយដើម្បីបានសំណងរដ្ឋប្បវេណីគឺជនរងគ្រោះត្រូវបន្តចូលក្នុងនីតិវិធីអនុវត្ត ដោយគាត់ចាប់ផ្តើមដោយការស្នើសុំទៅតុលាការអនុវត្ត ។
- **ករណីជនល្មើស ឬមេខ្យល់នៅក្រៅប្រទេស** ៖ ករណីនេះពួកគេតែងតែអវត្តមានចូលរួមក្នុងនីតិវិធីតុលាការ ដែលនាំឲ្យមានការពិបាកក្នុងការផ្តន្ទាទោស និងអូសបន្លាយនីតិវិធីយូរ ។ ករណីនេះមិនស្ថិតក្នុងវិសាលភាពនៃការអនុវត្តកិច្ចព្រមព្រៀងស្តីពីបត្យាប័ន និងកិច្ចព្រមព្រៀង ស្តីពីការបញ្ជូនទណ្ឌិតដែលក្រសួងបានចុះជាមួយប្រទេសមួយចំនួនទេ ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងយុត្តិធម៌ត្រូវចុះសន្ធិសញ្ញាស្តីពីជំនួយទៅវិញទៅមកផ្នែកយុត្តិធម៌ក្នុងវិស័យព្រហ្មទណ្ឌ ដែលបច្ចុប្បន្នបានចុះជាមួយវៀតណាម និងកំពុងរៀបចំសេចក្តីព្រាងជាមួយថៃ ។

**ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលការងារពាក់ព័ន្ធនឹងការអនុវត្តច្បាប់ ដើម្បីយុត្តិធម៌ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងទិដ្ឋភាពច្បាប់ផ្សេងៗដែលក្រសួងបានបំពេញក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដើម្បីជួយជនរងគ្រោះដោយអំពើជួញដូរ ដែលជាលទ្ធផលក្រសួងបានបង្កើនការពង្រឹងការអនុវត្តច្បាប់ អនុសញ្ញា កតិកាសញ្ញាអន្តរជាតិ ច្បាប់ជាតិ អនុស្សរណៈ និងកិច្ចព្រមព្រៀងទ្វេភាគី-ពហុភាគី និងផែនការសកម្មភាពជាតិ និងបទដ្ឋានគតិយុត្តិទាំងឡាយឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ ស្របតាមស្ថានភាពជាក់ស្តែង ។ មិនតែប៉ុណ្ណោះក្រសួងមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ដែលជាសេនាធិការក្នុងការបំពេញការងារជួយជនរងគ្រោះ ដោយបានសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធ ទទួលបានលទ្ធផលល្អប្រសើរ ក្នុងការសម្របសម្រួលសាក្សី និងជនរងគ្រោះ ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពានផ្លូវភេទ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះពីបរទេស ការធ្វើសមាហរណកម្មទៅសហគមន៍ និងការរៀបចំគោលនយោបាយ ច្បាប់ និងបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងជនរងគ្រោះ ។

**ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានធ្វើសេចក្តីរាយការណ៍អំពី ដំណោះស្រាយវិវាទសម្រាប់ពលករទេសន្តរប្រវេសន៍ ក្នុងចំណោមពលករដែលបានចេញទៅធ្វើការនៅបរទេស តាមរយៈក្រុមហ៊ុនជាទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ ៖ ក្នុងការគ្រប់គ្រងលើការបញ្ជូនពលករ ក្រសួងបានរៀបចំ និងអនុវត្តតាមគោលនយោបាយ បទបញ្ជា និងនីតិវិធីស្របតាមច្បាប់ ដោយមានយន្តការសមស្របសម្រាប់អនុវត្តធានាបាននូវការការពារ និងការលើកកម្ពស់សិទ្ធិពលករ ។ ក្រសួងក៏មានក្រុមមន្ត្រីអធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន ទទួលបន្ទុកឃ្លាំមើល និងធ្វើការណែនាំតម្រង់ទិសការអនុវត្ត

របស់ទីភ្នាក់ងារជ្រើសរើសឯកជនជាប់ជាប្រចាំ តែទោះយ៉ាងណាក៏នៅមានកើតឡើងនូវអំពើអសកម្មមួយចំនួន ដែលបានធ្វើឲ្យកើតមានឡើងនូវការកេងប្រវ័ញ្ច និងការជួញដូរកម្លាំងពលកម្មក៏ដូចជាការជួញដូរមនុស្ស។ ឆ្លើយតបនឹងបញ្ហាទាំងនេះ ប្រព័ន្ធដោះស្រាយវិវាទសម្រាប់ពលករទេសន្តប្រវេសន៍កម្ពុជាត្រូវបានបង្កើតឡើង និងដាក់ឲ្យដំណើរការនៅខេត្តមួយចំនួន និងកំពុងបន្តឲ្យបានគ្រប់ខេត្ត ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃសេវា និងបង្អិតសេវានៃការដោះស្រាយវិវាទឲ្យបានចូលទៅកាន់តែជិតប្រជាពលរដ្ឋ ។ បច្ចុប្បន្ន មានទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ចំនួន ៧១ក្រុមហ៊ុន ដែលក្នុងនោះកំពុងដំណើរការមានចំនួន ៥៩ និងមិនដំណើរការចំនួន ១២ ។ ក្នុងឆ្នាំ២០១៦ ក្រសួងបានធ្វើអធិការកិច្ច និងបានចាត់វិធានការដោះស្រាយបញ្ហាដែលកើតឡើងចំពោះពលករដោយមានការដាក់កំហិតឲ្យក្រុមហ៊ុនរៀបចំបែបបទ និងលក្ខខណ្ឌឲ្យបានត្រឹមត្រូវ ការផ្អាកដំណើរការក្រុមហ៊ុនសម្រាប់ទុកពេលដោះស្រាយ និងការបញ្ឈប់ជាស្ថាពរករណីមិនអាចអនុវត្តបានត្រឹមត្រូវតាមការកំណត់ និងបានដោះស្រាយវិវាទបានសះជាជាច្រើនករណី ។

បន្ទាប់ពីតំណាងក្រសួងពាក់ព័ន្ធបញ្ចប់សេចក្តីរាយការណ៍ **សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី និងជាប្រធាន គ.ជ.ប.ជ** បានមានប្រសាសន៍បើកអង្គសិក្ខាសាលាថា ៖ ការរៀបចំសិក្ខាសាលាថ្នាក់ជាតិនេះ គឺដើម្បីសិក្សាអំពីស្ថានភាពជាក់ស្តែងដែលមាននៅក្នុងសង្គម ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលនៅមិនទាន់មានភាពល្អប្រសើរឆ្លើយតបទៅនឹងបំណងប្រាថ្នានៃការកសាងច្បាប់ ។ ជាគោលការណ៍អន្តរជាតិក៏ដូចជាក្នុងច្បាប់ជាតិ ជនរងគ្រោះចាំបាច់ត្រូវទទួលបានកិច្ចការពារសមស្របពីរដ្ឋាភិបាល តែក្នុងការអនុវត្តច្បាប់ជួញដូរមនុស្សជនរងគ្រោះជាច្រើនមិនទាន់បានទទួលការគាំពារផ្នែកច្បាប់ពេញលេញនៅឡើយ ព្រោះពួកគាត់មិនដឹងថាត្រូវធ្វើដូចម្តេចទើបអាចទទួលបានការការពារ ឬមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីបន្តនីតិវិធីច្បាប់ដ៏ស្មុគស្មាញ និងអូសបន្លាយរបស់តុលាការ ។ ប្រជាពលរដ្ឋដែលត្រូវបានគេបោកបញ្ឆោតឬជួញដូរ ឬកេងប្រវ័ញ្ច ឬប្រើហិង្សាលោភបំពានទាំងនោះ គាត់ត្រូវការឲ្យសមត្ថកិច្ច ឬអាជ្ញាធរជួយអន្តរាគមន៍ និងត្រូវការតុលាការជួយរកយុត្តិធម៌ តែដោយសារនីតិវិធីតុលាការមានភាពស្មុគស្មាញ និងអូសបន្លាយ ធ្វើឲ្យពួកគាត់ត្រូវចំណាយពេលវេលា និងថវិកាជាច្រើន តែទីបំផុតមានករណីជាច្រើនដែលរកមិនឃើញកំហុសជនសង្ស័យ ឬបង្វែរបទចោទ ឬត្រូវដោះលែង ព្រោះមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកជាដើម ហើយពេលខ្លះទោះបីជាចេញសាលក្រមពីតុលាការសម្រេចទោសហើយក្តីក៏មិនទទួលបានសំណងប៉ះប៉ូវការខូចខាតអ្វីដែរ ហើយជនល្មើសនៅតែអាចបន្តប្រព្រឹត្តបទល្មើសបានយ៉ាងងងើល ។ បញ្ហានេះបានបង្កើតឲ្យមាននូវការថ្នាំងថ្នាក់ពីប្រជាពលរដ្ឋរងគ្រោះកាន់តែច្រើនឡើងៗ ដែលទាមទារឲ្យមានការពិនិត្យ និងពិភាក្សាគ្នាឡើងវិញ អំពីបែបបទ នីតិវិធី និងភាពខ្វះចន្លោះនៃបទដ្ឋានច្បាប់ ឬការអនុវត្ត ដែលគប្បីត្រូវកែលម្អជាបន្ទាន់ ដើម្បីជាគន្លឹះដោះស្រាយបញ្ហា និងឆ្លើយតបទៅនឹងចំណុចខ្វះចន្លោះ និងភាពប្រឈមទាំងឡាយដែលនាំឲ្យប្រជាពលរដ្ឋមានកង្វល់ ហើយនៅតែប្រថុយប្រថាននឹងគ្រោះថ្នាក់ជាបន្តបន្ទាប់ ។

សម្តេចបានសំណូមពរឲ្យអង្គសិក្ខាសាលាទាំងមូល ដែលមានមន្ត្រីជំនាញជាន់ខ្ពស់ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ ត្រូវធ្វើការសិក្សា ផ្លាស់ប្តូរយោបល់ និងចែករំលែកបទពិសោធន៍គ្នាឲ្យបានល្អិតល្អន់ ដើម្បីរិះរកនីតិវិធី ឬដំណោះស្រាយឆ្លើយតបចំពោះបញ្ហាប្រឈមទាំងឡាយ ដើម្បីផ្តល់យុត្តិធម៌ជូនជនរងគ្រោះឲ្យបានពេញលេញ ។ សម្តេចបានបញ្ជាក់ថា សម្តេចគាំទ្រណាស់ក្នុងការរួមគ្នារកនីតិវិធីដោះស្រាយ ព្រោះជនរងគ្រោះគ្នាខ្សោយទៅហើយ បើរាជរដ្ឋាភិបាលមិនយកចិត្តទុកដាក់ទៀតនោះគាត់នឹងកាន់តែលំបាក ។ សម្តេចបានផ្តល់អនុសាសន៍និងសំណូមពរមួយចំនួនចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលមានដូចខាងក្រោម ៖

- ធ្វើយ៉ាងណាកាត់បន្ថយនីតិវិធីដែលមិនចាំបាច់ ដើម្បីផលប្រយោជន៍ជនរងគ្រោះ ដែលមានផលប្រយោជន៍ពីការកាត់ក្តីរបស់តុលាការ និងមួយទៀតគឺចំណេញពេលវេលា និងថវិកា ។
- ការអប់រំផ្សព្វផ្សាយមានសារសំខាន់ណាស់ដើម្បីឲ្យពលរដ្ឋយល់ដឹង និងការពារផលប្រយោជន៍របស់ខ្លួន ដូចនេះត្រូវបន្តជំរុញការផ្សព្វផ្សាយឲ្យកាន់តែទូលំទូលាយ ។
- ដើម្បីការងារបានជោគជ័យត្រូវពឹងលើការសហការរួម ចូលរួមច្រើនបានកាលណានឹងកាន់តែទទួលបានជោគជ័យ ដូចនេះយើងត្រូវរួមគ្នាដោះស្រាយ មិនពឹងផ្អែកតែលើសមត្ថកិច្ចទេ តែសមត្ថកិច្ចត្រូវជាគោល ។
- កន្លងមកក្រសួងមហាផ្ទៃធ្លាប់បានណែនាំឲ្យបណ្តាខេត្តជាប់ព្រំដែនបិទរបៀង ព្រោះមានប្រកច្រើនហើយ មិនមានហេតុផលអ្វីត្រូវបើករបៀងទៀតទេ តែក៏មិនហាមឃាត់មិនបើកដែរ បើបើកតែត្រូវមានអ្នកការពារ ព្រោះមានបទល្មើសជាច្រើនឆ្លងកាត់តាមនោះ ។
- សូមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើការគ្រប់គ្រងក្រុមហ៊ុនដែលជាទីភ្នាក់ងារឯកជននាំពលករ ឲ្យបានត្រឹមត្រូវ និងច្បាស់លាស់ ។
- តួអង្គសំខាន់គឺ តុលាការ និងក្រសួងយុត្តិធម៌ សូមជ្រាបថា បញ្ហាមិនត្រឹមតែពាក់ព័ន្ធជួញដូរទេ គឺពាក់ព័ន្ធបញ្ហាដទៃទៀត ដូចនេះតួអង្គតុលាការ និងក្រសួងយុត្តិធម៌ សូមឲ្យគាំទ្រផង ។
- ទទួលស្គាល់ថាការងារវាលេចអណ្តែត តែសូមធ្វើយ៉ាងណា ឡើងហើយកុំឲ្យធ្លាក់វិញ (បានលេខ២ហើយ កុំឲ្យធ្លាក់ទៅលេខ២ឃ្លាំមើលវិញ) ។

ជាបន្ត **លោកជំទាវ ជូ ប៊ុនអេង** បានដឹកនាំអង្គសិក្ខាសាលាធ្វើការពិភាក្សាវិភាគនីតិវិធី និងដំណោះស្រាយស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម** ដែលកិច្ចពិភាក្សាបានចាប់ផ្តើមដោយបទអន្តរាគមន៍របស់ក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ ៖

**ឯកឧត្តម ឧ.ឯក ប៉ុល តិចេយ្យ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស** បានធ្វើបទអន្តរាគមន៍អំពីការងារអនុវត្តច្បាប់ ៖

- **ស្ថានភាពឧបាយកលថ្មីៗរបស់ជនល្មើសក្នុងឆ្នាំ២០១៦** ៖ ក្នុងឆ្នាំ២០១៦នេះ ករណីជួញដូរមនុស្សមានលេចចេញនូវទម្រង់ថ្មីៗមួយចំនួនដូចជា ៖
  - បញ្ហាទូកនេសាទលេចចេញនូវទម្រង់ថ្មីមួយ គឺនាំចូលប្រទេសវៀតណាមរួចឆ្លងទៅប្រទេសថៃ។
  - អាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ គឺជិះរថភ្លើងកាត់តាមប្រទេសវៀតណាមឆ្លងចូលប្រទេសចិន ។
  - ករណីពពោះជំនួស ដែលទើបតែលេចចេញក្នុងពេលថ្មីៗនេះ ។
- **ដំណាក់កាលយុត្តិធម៌ជនរងគ្រោះ ៖**
  - សូមអរគុណចៅក្រម-ព្រះរាជអាជ្ញាដែលតែងតែសហការល្អជាមួយនគរបាល ។
  - ក្នុងដំណាក់កាលកសាងសំណុំរឿង នគរបាលមានពេលតែ៤៨ម៉ោង ដែលមានផលលំបាកក្នុងការប្រមូលភស្តុតាង ហើយភស្តុតាងសំខាន់គឺភស្តុតាងកោសល្យវិច័យ ។ ចំពោះការសុើបសួរកុមារគឺមានការលំបាក ព្រោះកុមារមានការភ័យខ្លាច និងអាចផ្លាស់ប្តូរចម្លើយគ្រប់ពេល ។
  - សំណូមពរឲ្យខាងតុលាការ អញ្ជើញនគរបាលចូលរួមសវនាការជាសាក្សីដើម្បីបញ្ជាក់បន្ថែមអំពីសំណុំរឿង ។
  - សំណូមពរឲ្យខាងតុលាការ អញ្ជើញនគរបាលចូលរួមពេលប្រកាសសាលក្រម ព្រោះមន្ត្រីនគរបាលត្រូវស្រង់ទិន្នន័យធ្វើរបាយការណ៍ជូន គ.ជ.ប.ជ គឺដើម្បីដឹងថាសំណុំរឿង ដែលខ្លួនបាន

បញ្ជូនមកមានប៉ុន្មានករណីត្រូវចោទ កំពុងកាត់ក្តី ឬប្រកាសសាលក្រម ។ ទិន្នន័យ ដែលបាន កន្លងមកនេះ គឺនគរបាលបានយកទិន្នន័យរបស់ខ្លួនទៅពិនិត្យនៅពន្ធនាគារ ។

- **ការសហការគ្នា ៖** កន្លងមក នគរបាលបានសហការជាមួយក្រសួងការបរទេសក្នុងការបញ្ជូនព័ត៌មានឲ្យគ្នាទៅវិញទៅមក ហើយក៏បានសហការជាមួយនគរបាលប្រទេសនានាដូចជា ថៃ វៀតណាម ចិន ក្នុងការរួមគ្នាស៊ើបអង្កេតបទល្មើស និងបញ្ជូនព័ត៌មានឲ្យគ្នាទៅវិញទៅមក ដោយមានការឧបត្ថម្ភពីអង្គការមួយចំនួន ។
- **បញ្ហាសំណងជនរងគ្រោះ ៖** កន្លងមក ជនរងគ្រោះតែងសង្ឃឹមទទួលបានសំណងទាន់ពេលវេលា តែនីតិវិធីតុលាការវែង ធ្វើឲ្យពួកគាត់អស់សង្ឃឹម ។ ចំពោះការកាត់ទោសជនល្មើសនៅក្រៅប្រទេស គឺមានជនរងគ្រោះធ្លាប់ទទួលបានសំណង ដោយមានការជួយគាំទ្រពីអង្គការពាក់ព័ន្ធ ។

**ឯកឧត្តម អ៊ុក សាវុធ អគ្គនាយកព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍** បានចែករំលែកចំណេះដឹង និងបទពិសោធន៍ ព្រមទាំងលើកនូវសំណូមពរមួយចំនួនដើម្បីជាគន្លឹះក្នុងការរិះរកដំណោះស្រាយ ដែលមានដូចខាងក្រោម ៖

- **ឆ្លើយតបសំណូមពររបស់ ឯកឧត្តម ឧ.ឯក ប៉ុលភិធេយ្យ ៖** ចំពោះនីតិវិធីកោះហៅនគរបាលចូលរួមពេលកាត់ក្តី ពេលនោះនគរបាលមិនមែនជាសាក្សីទេ គាត់ចូលតុលាការគឺដើម្បីស្រាយបំភ្លឺចំណាត់ការរបស់គាត់ ។
- **នីតិវិធីទារសំណងឲ្យជនរងគ្រោះ ៖** ឯកឧត្តមទទួលស្គាល់ថា នីតិវិធីតុលាការវែងមែន តែច្បាប់តម្រូវយ៉ាងនេះ ។ កន្លងមក ជនរងគ្រោះបានតែសម្រេចឈ្នះក្តី តែមិនដឹងធ្វើយ៉ាងម៉េចដើម្បីបានសំណង ព្រោះគាត់ក្រីក្រមិនដឹងសរសេរពាក្យបណ្តឹងយ៉ាងម៉េចទេ ទាល់តែក្រឡាបញ្ជីជួយ ។ ក្នុងករណីគ្មានសំណងទើបមានវិធានការដាក់ពន្ធនាគារ ។ ឯកឧត្តមបានគាំទ្រចំពោះការរិះរកនីតិវិធី ឬដំណោះស្រាយ ឬធ្វើវិសោធនកម្ម ដើម្បីឲ្យនីតិវិធីខ្លីជាងមុន ហើយជនរងគ្រោះទទួលបានសំណងពេញលេញ មិនចំណាយពេលវេលា និងថវិកាច្រើន ។
- **ករណីទារសំណងនៅក្រៅប្រទេស ៖** នៅក្នុងអាស៊ាន គ្រប់ប្រទេសមានបង្កើតអាជ្ញាធរកណ្តាល បើការទារសំណងត្រូវឆ្លងកាត់អាជ្ញាធរកណ្តាលគឺលឿន និងមានប្រសិទ្ធភាព តែបើធ្វើតាមកិច្ចព្រមព្រៀងគឺវែងឆ្ងាយ ។
- សូមចៅក្រម-ព្រះរាជអាជ្ញាត្រឡប់ទៅវិញផ្សព្វផ្សាយប្រាប់គ្នា ត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាជួញដូរមនុស្ស និងត្រូវធ្វើការតាមនីតិវិធីឲ្យបានលឿន កុំទុកចោល ។
- សូមមន្ត្រីនគរបាលយុត្តិធម៌ រក្សាវត្ថុតាង និងធ្វើកំណត់ហេតុឲ្យបានត្រឹមត្រូវ ព្រោះចៅក្រម-ព្រះរាជអាជ្ញាមើលតែតាមកំណត់ហេតុទេ អ្នកដែលដឹងមុនគេគឺអ្នកកត់កំណត់ហេតុ ដូចនេះលទ្ធផលនៃការកាត់ក្តីក៏ទៅតាមនោះដែរ ។ សូមធ្វើឲ្យបានជាក់លាក់តាមអំពើរបស់ជនល្មើស (គ្រប់ប្រភេទករណី) ព្រោះជនល្មើស និងជនរងគ្រោះស្រែករកយុត្តិធម៌ដូចគ្នា ។

បន្ទាប់មក អង្គសិក្ខាសាលាបានឈានដល់កិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ និងចែករំលែកចំណេះដឹង និងបទពិសោធន៍ជូនគ្នាទៅវិញទៅមក ដោយមានខាងចៅក្រម-ព្រះរាជអាជ្ញាមកពីបណ្តារាជធានី-ខេត្ត ឡើងធ្វើជាវាគ្មិន ហើយកិច្ចពិភាក្សាទទួលបានលទ្ធផលដូចតទៅ ៖

១. ដំណើរការសំណុំរឿង

នៅពេលស្ថាប័នអយ្យការទទួលសំណុំរឿងពីនគរបាល នីតិវិធីមានដូចតទៅ ៖

- **ដំណាក់កាលអយ្យការ** ៖ ព្រះរាជអាជ្ញា-ព្រះរាជអាជ្ញារង ធ្វើការសាកសួរ រួចសម្រេចថា តម្កល់ទុកមិនចាត់ការ ឬបញ្ជូនទៅចៅក្រមស៊ើបសួរ ។
- **ដំណាក់កាលស៊ើបសួរ** ៖ ចៅក្រមស៊ើបសួរបើកការស៊ើបអង្កេត និងពិនិត្យភស្តុតាង(ធ្វើគ្រប់នីតិវិធី) បើមិនមានភស្តុតាងនោះនឹងបិទការចោទប្រកាន់ តែបើមានភស្តុតាងគ្រប់គ្រាន់នោះនឹងបញ្ជូនបន្តទៅចៅក្រមជំនុំជម្រះ ។
  *(ក្នុងដំណាក់កាលនេះ ត្រូវធ្វើការបញ្ជាក់ជនរងគ្រោះតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នោះនឹងធ្វើការកាត់ក្តីសំណងក្នុងដំណាក់កាលជំនុំជម្រះតែម្តង តែបើមិនបានតាំងខ្លួនទេគឺ មិនទាន់កាត់ក្តីទេ)*
- **ដំណាក់កាលជំនុំជម្រះ** ៖ បើរកមិនឃើញពិរុទ្ធភាពនោះអាចរួចពីការចោទ តែបើរកឃើញពិរុទ្ធភាពនោះនឹងធ្វើការកាត់ទោសនិងទារសំណង ។

**២. ដំណើរការទារសំណង**

- បន្ទាប់ពីចៅក្រមជំនុំជម្រះ ចេញសាលក្រមស្ថាពរ អ្នកទារសំណងរដ្ឋប្បវេណីត្រូវដាក់ពាក្យសុំអនុវត្តទារសំណង ទៅតុលាការរដ្ឋប្បវេណី (មិនមែនដាក់ទៅតុលាការព្រហ្មទណ្ឌទេ) ។ ពេលតុលាការសម្រេចឲ្យអនុវត្តទារសំណង នោះជាសមត្ថកិច្ចរបស់តំណាងអយ្យការត្រូវអនុវត្តទារសំណង (ការអនុវត្តសំណងនេះនៅតែអនុវត្ត ទោះជាចុងចោទកំពុងជាប់ពន្ធនាគារក៏ដោយ) តែបើចុងចោទមិនមានសំណងទេ នោះនឹងត្រូវដាក់ពន្ធនាគារបន្ថែម ។
- ករណីចុងចោទមិនមានសំណង អ្នកទារសំណងត្រូវស្វែងរកទ្រព្យរបស់ចុងចោទដោយខ្លួនឯង ដើម្បីប្រាប់ទៅតុលាការឲ្យចាត់ការ ។
- អ្នកទារសំណងរដ្ឋប្បវេណីត្រូវមានសោហ៊ុយខ្លះដើម្បីដំណើរការសំណុំរឿង តែកន្លងមកមានខ្លះដល់ចប់ ខ្លះបានពាក់កណ្តាល ហើយករណីនេះអង្គការ AAPTIP ជួយគាំទ្រសម្របសម្រួលដល់ជនរងគ្រោះ ។
- ការទូទាត់សំណងក្រៅប្រព័ន្ធតុលាការគឺបាន តែបណ្តឹងអាជ្ញានៅតែបន្ត ។

**៣. មតិយោបល់ពាក់ព័ន្ធ**

- **ដើម្បីឲ្យទទួលបានសំណងឆាប់គឺ** ៖ ធ្វើយ៉ាងណាឲ្យបានសាលក្រមស្ថាពរលឿន ដោយអាជ្ញាធរតុលាការចាត់ការឆាប់ និងអាជ្ញាធរមូលដ្ឋាន និងអង្គការជួយ ហើយពេលចេញសាលក្រមស្ថាពរភ្លាមត្រូវដាក់ពាក្យសុំអនុវត្តទៅចៅក្រមអនុវត្តភ្លាម ។
- ការបង្កកទ្រព្យអាចដកហូតមកសងបានលុះត្រាមានសេចក្តីសម្រេចជាលិខិតអនុវត្ត ។
- មាត្រា៤៧ ៖ វត្ថុរឹបអូសជាសម្បត្តិរដ្ឋ មិនអាចយកមកធ្វើជាសំណងបានទេ ។
- ការហៅនគរបាលចូលសវនាការដើម្បីការពារភស្តុតាង និងបង្ហាញប្រតិបត្តិការ មិនតម្រូវឲ្យស្បថទេ ។
- ក្នុងសវនាការគេមិនដាក់គុកៅអីឲ្យនគរបាលទេទោះករណីអ្វីក៏ដោយ ។
- **តំណាងអង្គការ APLE** ៖ ករណីជនល្មើសជាជនបរទេស គឺត្រូវរកសញ្ញាណនៃទ្រព្យ គួរឲ្យសមត្ថកិច្ចសហការជាមួយអាជ្ញាធរបរទេស (កន្លងមកបានសហការជាមួយអាជ្ញាធរក្រៅប្រទេសក្រៅផ្លូវការ ឲ្យជួយរក) ហើយពេលចេញសាលក្រម គួរបញ្ជូនទៅតាមស្ថានទូតដើម្បីឲ្យជួយសម្របសម្រួល ។
- លោក **ប៉ា វណ្ណៈ មកពីនាយកដ្ឋានជំនួយទៅវិញទៅមក និងបត្យាប័ន នៃក្រសួងយុត្តិធម៌ ៖** ឆ្នាំ២០១១ ក្រសួងយុត្តិធម៌បានបង្កើតអាជ្ញាធរកណ្តាល ដើម្បីឲ្យសមត្ថកិច្ចដោះស្រាយតាមរយៈនេះ តែតាំងពីឆ្នាំ២០១១មកមិនទាន់មានអ្នកដាក់ទៅទេ ។ កម្ពុជាមិនទាន់មានច្បាប់ជំនួយផ្លូវច្បាប់ទៅវិញទៅមក

ផ្នែកព្រហ្មទណ្ឌទេ គឺកំពុងព្រាង ដោយមានជំនួយពី AAPTIP ។ ករណីត្រូវបញ្ជូនមកតាមក្រសួងការបរទេស រួចបញ្ជូនបន្តមកក្រសួងយុត្តិធម៌ រួចបន្តមកអាជ្ញាធរកណ្តាលជាអ្នកចាត់ការបន្ត ។

- ដំណោះស្រាយជនរងគ្រោះក្រៅប្រទេស ៖
  - ករណីថៅកែមិនបើកប្រាក់ខែឲ្យ (មិនស្របច្បាប់) ស្ថានទូតមានតែទំនាក់ទំនងទៅថៅកែ ដើម្បីសម្របសម្រួល (គំរាមប្តឹង បើមិនសង) ។
  - ករណីថៅកែមិនបើកប្រាក់ខែឲ្យ (ស្របច្បាប់) ស្ថានទូតទាក់ទងក្រុមហ៊ុន ឬទីភ្នាក់ងារ ដើម្បីធ្វើការដោះស្រាយ ។
  - ករណីពលករត្រឡប់មកវិញហើយតែមិនទាន់ទទួលបានសំណង បើស្របច្បាប់ គួរដាក់ពាក្យទៅក្រសួងការងារ រួចបញ្ជូនបន្តទៅក្រសួងការបរទេស ។

ជាទីបញ្ចប់ **លោកជំទាវ ជូ ម៉ុនអេង** បានមានប្រសាសន៍សរុបមតិបិទអង្គសិក្ខាសាលាថា ៖ សិក្ខាសាលាថ្ងៃនេះជាជំហានទីមួយ ហើយលទ្ធផលនេះគ្រាន់តែជាការចាប់ផ្តើមសម្រាប់ជាមូលដ្ឋានសម្រាប់ការជួបគ្នាពិភាក្សាបន្តនាពេលក្រោយ ព្រោះបញ្ហានៅមានច្រើនដែលត្រូវការពេលវេលាដើម្បីរិះរកដំណោះស្រាយបន្ត។ យើងនឹងរក្សាលទ្ធផលថ្ងៃនេះទុក ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំដើម្បីទទួលបានវិធានការ និងអនុសាសន៍ថ្មីៗបន្ថែមទៀត ដូចនេះយើងទាំងអស់គ្នានឹងរួមគ្នាគិតបន្តក្នុងការស្វែងរកនីតិវិធីដែលដំណើរការទៅដោយរលូន ដើម្បីផ្តល់នូវសេចក្តីសុខពេញលេញជូនប្រជាពលរដ្ឋ ។

សិក្ខាសាលាបានបញ្ចប់នៅវេលាម៉ោងដប់ប្រាំពីរល្ងាច ថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី១៧ខែមករាឆ្នាំ២០១៧

**អ្នកកត់ត្រា**

គោរពជូន លោកជំទាវ

អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបជាខ្ពង់ខ្ពស់ ។

ភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧

**ប្រធានលេខាធិការដ្ឋាន**

ឧត្តមសេនីយ៍ត្រី **គង់ ពុទ្ធី**

02/02/17

ជូ ម៉ុនអេង